# ឧបករណ៍តន្ត្រី «ពាទ្យ»

**ពាទ្យ** ជាប្រភេទគ្រឿងដំនិងជាឧបករណ៍តន្ត្រីដ៏ចាស់មួយនៅក្នុងចំណោមឧបករណ៍តន្ត្រីខ្មែរទាំងអស់ ដោយមានទាំងរូបចម្លាក់បួន (ពាទ្យផ្ទៃ៨ ពីរ និង ផ្ទៃ៩ ពីរ) ឆ្លាក់នៅលើជញ្ជាំងប្រាសាទអង្គរវត្ត (ថែវខាងជើង) ជាតឹកតាង។ យើងគួរកត់សម្គាល់ថា ឯកសារចាស់ៗនៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ បានឱ្យនិយមន័យទៅលើពាក្យ "**ពាទ្យ**" ថា "**ឧបករណ៍តន្ត្រី**"។[១] ឯចំណែកសម្តេចព្រះសង្ឃរាជ ជួន ណាត បានឱ្យនិយមន័យទៅលើពាក្យ "**ពាទ្យ**" ថា៖ ជាគ្រឿងភ្លេងប្រគំ, គ្រឿងតន្ត្រីដេញដំផ្ទុំកូតឬគ្រឿងតន្ត្រីទូទៅគ្រប់យ៉ាង។ ពាក្យនេះ ខ្មែរប្រើជាបរិវាសព្ទផ្សំនឹងពាក្យ ពិណ ថា៖ ពិណពាទ្យ គឺគ្រឿងភ្លេងដេញដំផ្ទុំមានពិណាគឺ ចាប៉ីជាដើម។[២]

ឧបករណ៍ពាទ្យ មានផ្ទៃប្រាំបីនិងប្រាំបួនរៀបជាជួរពីឆ្វេងទៅស្តាំ សូរទាបទៅខ្ពស់ក្នុងរង្វង់រាងចំណិតខែឬស្នែងក្របី។ សព្វថ្ងៃ គេប្រើឧបករណ៍តន្ត្រីពាទ្យ នៅក្នុងវង់ភ្លេងត្រៃលក្ខណ៍ (ទ្រាមមីង កន្ទ្រាំមីង កន្ទាំមីង ទាំមីង កន្រ្ទឹមមីង ម៉ូងគ្រុំ ធម្មំ ធម្មមីង) រួមជាមួយនឹងឧបករណ៍តន្ត្រីមួយចំនួនទៀតមាន ស្រឡៃត្រៃលក្ខណ៍១ គងញីឬគងដោះ២ និងស្គរធំ១ លេងដោយតន្ត្រីករបីនាក់អង្គុយទល់ខ្នងគ្នាតំណាងឱ្យទស្សនៈត្រៃលក្ខណ៍ (អនិច្ចំ ទុក្ខំ អនត្តា) សេចក្តីស្លាប់ និងការបែកចេញពីគ្នា សម្រាប់កំដរពិធីតម្កល់និងលើកសព ជាពិសេសនៅខេត្តសៀមរាប ស្រុកសូត្រនិគម។[៣]

"**ពាទ្យ**" ជាឧបករណ៍តន្ត្រីបរមបុរាណរបស់ខ្មែរតាំងពីសម័យអង្គរ ឬមុននោះទៅទៀត។ យើងក៏អាចសន្មតបានថា ពាទ្យជាឧបករណ៍តន្ត្រីដើមដែលផ្តល់កំណើតនិងអភិវឌ្ឍន៍ដល់គងតូចនិងគងធំប្រើនៅក្នុងវង់តន្ត្រីពិណពាទ្យសព្វថ្ងៃ។ នាបច្ចុប្បន្នឧបករណ៍តន្ត្រី

---

[១] Janneau 1870: 115, Aymonier 1878: 300, Guesdon 1930: 1210

[២] ជួន ១៩៦៧: ៧៤៤

[៣] វង់តន្ត្រីត្រៃលក្ខណ៍នេះ មានឈ្មោះច្រើនដែលគេហៅខុសៗគ្នា (កែវ ២០១១: ២២០, ពេជ្រ ២០០៣: ២៩៦-២៩៨)

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

ពាទ្យសឹងតែបាត់បង់អស់ទៅហើយ ដោយខ្មែរយើងពុំសូវប្រើវង់តន្ត្រីគ្រែលក្ខណ៍ និងមិនធ្វើពិធីតម្កល់និងលើកសពទៀតឡើយ លើកលែងតែនៅក្នុងតំបន់ខ្វះតិចតួចតែប៉ុណ្ណោះ។

យើងគួរលើកជាសំណួរមួយចំនួន ដើម្បីរកចម្លើយឱ្យយល់ដឹងបន្ថែម និងស៊ីជម្រៅជាពិសេសសម្រាប់អ្នកស្រាវជ្រាវថា ហេតុអ្វីបានជាពាទ្យមានផ្ទៃ៨និង៩? ដោយឧបករណ៍ពាទ្យបានឱ្យកំណើតដល់គងវង់តូចនិងគងវង់ធំ តើអាចទេដែលពាទ្យផ្ទៃ៩ ជាមេរបស់គង វង់តូច និងពាទ្យផ្ទៃ៨ ជាមេរបស់គងវង់ធំ?



អត្ថបទដោយ៖ បណ្ឌិត សំ សំអាង



## ឯកសារពិគ្រោះ

កែវ ណារុំ. (២០១១). *តន្ត្រីនៅប្រទេសខ្មែរ*. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។

ជួន ណាត. (១៩៦៧). *វចនានុក្រមខ្មែរ*. ភ្នំពេញ: ពុទ្ធសាសនបណ្ឌិត្យ។

ពេជ្រ ទុំក្រវិល. (២០០៣). *ទស្សនីយភាពខ្មែរ*. ភ្នំពេញ: រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា។

Aymonier, Etienne. (1878). *Dictionnaire Khmer- Français*. Saigon: n.p.

Guesdon, Joseph. (1930). *Dictionnaire Cambodgien-Français*, 2 vols. Paris: Librairie d'Amérique et d'Orient, I-II.

Janneau, Gustav Jean Auguste. (1870). *Manuel Pratique*. Saigon: Imprimerie Impériale.

*Musique Khmère*. (1969). Phnom Penh: Imprimerie Sangkum Réastr Niyum.

Sam, Sam-Ang. (1988). *Pin Peat Ensemble: Its Fundamental, Music, and Context*. Ph.D. Dissertation, Wesleyan University. (p. 23)

________. (2002). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង